# តើ‹‹លោក ប៊ុន-រដ្ឋា›› ធ្វើអបគមន៍ដូច ហ៊ុន-សែន ចោទដែរឬទេ?

ដោយសារតែ**លោកប៊ុន-រដ្ឋា** ត្រូវបាន**ហ៊ុន-សែន** លាបពណ៌ថា **បង្កើតតំបន់អបគមន៍ប្រឆាំងរដ្ឋាភិបាល និងមានផែនការផ្តួលរំលំរដ្ឋាភិបាលស្របច្បាប់ តាមរយៈជំម្លោះដីធ្លីខេត្តក្រចេះ**ជាមួយ**លោកម៉ម-សុណង់ដូ** នោះ បានធ្វើអោយខ្មែរអ្នកស្នេហាជាតិនៅក្រៅប្រទេសជាច្រើនចង់ដឹងចង់ឮអំពីពត៌មាន**លោកប៊ុនរ-រដ្ឋា** ហើយពាក្យចចាមអារាមអំពី **លោកប៊ុន-រដ្ឋា** ខុសៗគ្នា តែងតែលិចឮខ្ទរខ្ទារទៅតាមទំនោរនិន្នាការនយោបាយរបស់អ្នកឃោសនា។

តើ**លោកប៊ុន-រដ្ឋា** កំពុងស្ថិតនៅទីណា?

តើ**លោកប៊ុន-រដ្ឋា** បានធ្វើអបគមន៍ជាមួយ**លោកម៉ម-សុណង់ដូ** ដូចមេកន្រ្ទាញ**ហ៊ុន-សែន** បានចោទប្រកាន់ដែរឬទេ?

តើ**លោកប៊ុន-រដ្ឋា** មានស្ថានភាពលំបាកយ៉ាងដូចម្តេចដែរនៅក្នុងការរត់គេចចេញពីក្រញ៉ាំដៃបិសាចស្រេកឈាម**ហ៊ុន-សែន**នោះ?

ដើម្បីអោយដឹងច្បាស់ពីការពិត សូមបងប្អូនជនរួមជាតិខ្មែរទាំងអស់ស្តាប់ការបកស្រាយរបស់**ឪពុកលោកប៊ុន-រដ្ឋា**ឈ្មោះ**ប៊ុន-ឆន**ដូចតទៅនេះ៖





**លោកប៊ុន-ឆន** ជាឪពុក**លោកប៊ុន-រដ្ឋា** ថតនៅក្នុង **B.R.C** នៅថ្ងៃទី២៧ខែកុម្ភៈឆ្នាំ២០១៣, **លេខទូរសព្ទ័នៅក្នុងប្រទេសថៃឡង់៖ 0882277629**

‹‹**លោកប៊ុន-រដ្ឋា** កំពុងលាក់ខ្លួននិងផ្លាស់ទីពីកន្លែងទៅកន្លែងមួយយ៉ាងលំបាកលំបិននៅក្នុងប្រទេសថៃឡង់ដើម្បីគេចចេញពីការតាមចាប់របស់**ហ៊ុន-សែន**››។

សូមបញ្ជាក់ថា **លោកប៊ុន-រដ្ឋា** ត្រូវបានតុលាការរាជធានីភ្នំពេញកាត់ទោស កំបាំងមុខអោយជាប់ពន្ធនាគារ៣០ឆ្នាំ និងពិន័យជាប្រាក់១០លានរៀល តាមការប្រកាសសាលក្រមរបស់តុលាការរាជធានីភ្នំពេញ ចុះថ្ងៃទី១ខែតុលា ឆ្នាំ២០១២ ពីបទបង្កើតតំបន់អបគមន៍ប្រឆាំងរដ្ឋាភិបាល និងមានផែនការ ផ្តួលរំលំរដ្ឋាភិបាល តាមរយៈជំម្លោះដីធ្លីខេត្តក្រចេះ ហើយចំណែកឯ




លោកម៉ម-សុណង់ដូ

**លោក ម៉ម-សុណង់ដូ** ជាប្រធាន សមាគមន៍អ្នកប្រជាធិបតេយ្យ និងជា នាយកវិទ្យុសំបុកឃ្មុំ ដ៏មានប្រជាប្រិយភាព ត្រូវបានតុលាការរាជធានីភ្នំពេញ កាត់ទោសដាក់ពន្ធនាគារ ២០ ឆ្នាំ និងពិន័យជាប្រាក់១០លានរៀល ក្នុង រឿងក្តីបង្កើតតំបន់អបគមន៍ប្រឆាំងរដ្ឋាភិបាល តាមរយៈជម្លោះដីធ្លីនៅខេត្ត ក្រចេះ តាមការប្រកាសសាលក្រមរបស់តុលាការរាជធានីភ្នំពេញ ចុះថ្ងៃទី ១ខែតុលាឆ្នាំ២០១២។



**លោកប៊ុន-ឆន**
Tel: 0882277629

**លោកប៊ុន-ឆន** មានអាយុ៥៨ឆ្នាំ ដែលជាឪពុករបស់ **លោកប៊ុន-រដ្ឋា** បានមានប្រសាសន៍ប្រាប់ខ្ញុំនៅក្នុង មជ្ឈមណ្ឌលជនភៀសខ្លួនក្រុងបាងកក Bangkok Refugee Center (B.R.C) នៅពេលល្ងាចនៃថ្ងៃទី ២៧ខែកុម្ភៈឆ្នាំ២០១៣ ថា៖ បន្ទាប់ពីបានរៀនចប់, **លោកប៊ុន-រដ្ឋា** បានធ្វើការនៅក្រុមហ៊ុនអគ្គីសនីបារាំង នៅស្រុកឧត្តុងនៃខេត្តកំពង់ស្ពឺ ហើយបានឈប់ធ្វើការនៅឆ្នាំ២០១១ មកកិន ស្រូវនៅភូមិឈើខ្លឹម,ឃុំរំចេក, ស្រុកមេមត់, ខេត្តកំពង់ចាម។ **លោកប៊ុន-រដ្ឋា** បានជួយប្រជាជននៅស្រុកចំការលើ, ស្រុកស្ទឹងត្រង់, ស្រុកមេមត់ និងស្រុក កៀនស្វាយ ធ្វើញត្តិតវ៉ានៅខុទ្ទការល័យហ៊ុនសែនក្រុងភ្នំពេញនៅឆ្នាំ២០១១ ដើម្បីទាមទារដីធ្លីរបស់ពួកគាត់មកវិញហើយដោយសារតែអ្នកតវ៉ាអត់អង្គុរនិង

ម្ហូបហូបចុក **លោកប៊ុន-រដ្ឋា** ក៏បានទៅពឹងពាក់**លោកម៉ម-សុណង់ដូ**ហើយ **លោកម៉ម-សុណង់ដូ** ក៏បានផ្តល់អង្ករនិងម្ហូមម្ហារ ដល់អ្នកស្រុកដែលកំពុងតវ៉ាទាមទារដីធ្លីរបស់ពួកគាត់មកវិញ រហូតដល់រដ្ឋាភិបាលប្រគល់ដីធ្លីអោយពួកគាត់វិញ។ បន្ទាប់មកពួកអ្នកស្រុកឈ្នួល និងស្រុកស្លូងនៃខេត្តក្រចេះ ក៏បានពឹងពាក់**លោកប៊ុន-រដ្ឋា** អោយជួយតវ៉ាទាមទារដីធ្លីរបស់ពួកគាត់មកវិញ ហើយក៏មានរឿងរ៉ាវ ដោយតុលាការខេត្តក្រចេះបានចាប់ **លោកប៊ុន-រដ្ឋា** នៅថ្ងៃ៦ខែមេសាឆ្នាំ២០១២យកទៅឃុំខ្លួនចំនួន៣យប់និង៤ថ្ងៃហើយក៏ដោះលែងវិញ។ ក្រោយមករដ្ឋាភិបាល**ហ៊ុន-សែន**បានចាប់**លោកម៉ម-សុណង់ដូ**នៅថ្ងៃទី១៥ខែកក្កដាឆ្នាំ២០១២។ បន្ទាប់មក តុលាការរាជធានីភ្នំពេញបានកាត់ទោស**លោកម៉មសុណង់ដូ** ដាក់គុក២០ឆ្នាំនិង **លោកប៊ុន-រដ្ឋា** ដាក់គុក៣០ឆ្នាំ។

**លោកប៊ុន-ឆន** បានបន្តទៀតថា«**លោកប៊ុន-រដ្ឋា** មិនដែលស្គាល់**លោកសួន-សេរីរដ្ឋា** ឡើយ ហើយក៏មិនដែលជួប**លោកសួន-សេរីរដ្ឋា**ដែរ។ **លោកប៊ុន-រដ្ឋា** គ្រាន់តែបានជួប**លោកម៉ម-សុណង់ដូ** តែម្តងគត់! ហើយសព្វថ្ងៃនេះ **លោកប៊ុន-រដ្ឋា** ព្រមទាំងឪពុកម្តាយបងប្អូនបានមកដាក់ពាក្យសុំសិទ្ធិជ្រកកោណពីអង្គការ **UNHCR** នៃប្រទេសថៃឡង់ ហើយអង្គការ **UNHCR** នៃប្រទេសថៃឡង់បានសំភាសពួកគាត់រួចហើយ នៅថ្ងៃទី២៤ ខែមករាឆ្នាំ២០១៣ ប៉ុន្តែ **UNHCR** មិនទាន់ប្រកាសលទ្ធផលនៅឡើយទេ»។

**លោកប៊ុន-ឆន** ជាឪពុករបស់**លោកប៊ុន-រដ្ឋា** បានសូមអំពាវនាវដល់បងប្អូនខ្មែរនៅក្រៅប្រទេស សូមមេត្តាជួយកូនប្រុសរបស់គាត់ឈ្មោះ **ប៊ុន-រដ្ឋា** អោយបានរួចពីការតាមចាប់ខ្លួនរបស់រដ្ឋាភិបាល**ហ៊ុន-សែន**ផង ហើយសព្វថ្ងៃនេះ **លោកប៊ុន-រដ្ឋា** និងក្រុមគ្រួសារកំពុងរស់នៅយ៉ាងលំបាកលំបិន ខ្វះខាតសព្វគ្រប់ ព្រោះតែគេចភៀសខ្លួនពីតំបន់មួយទៅកាន់តំបន់មួយនៅក្នុងប្រទេសថៃឡង់នេះ មិនបានធ្វើការងារចិញ្ចឹមជីវិតទេ ហើយបើសិនជា **UNHCR** នៃប្រទេសថៃឡង់នៅតែពន្យាពេលទៀតនោះ

ទោះបីជា**លោកប៊ុន-រដ្ឋា** និងក្រុមគ្រួសារ មិនត្រូវបានរដ្ឋាភិបាលហ៊ុនសែនចាប់ ក៏គង់តែដាច់ពោះស្លាប់ដោយសារតែគ្មានអាហារបរិភោគដែរ។

បើបងប្អូនខ្មែរក្រៅប្រទេសណាមានចិត្តសប្បុរសចង់ជួយសង្គ្រោះលោក**ប៊ុន-រដ្ឋា** សូមទាក់ទងនឹងឪពុករបស់គាត់ឈ្មោះលោក**ប៊ុន-ឆន** តាមលេខទូរសព្ទ័នៅប្រទេសថៃឡង់ **Tel : 0882277629**

ដូច្នេះ**រដ្ឋាភិបាលហ៊ុន-សែន** ដែលចោទប្រកាន់**លោកប៊ុន-រដ្ឋាពីបទបង្កើតតំបន់អបគមន៍ប្រឆាំងរដ្ឋាភិបាល និងមានផែនការផ្តួលរំលំរដ្ឋាភិបាលតាមរយៈជំម្លោះដីធ្លីខេត្តក្រចេះ** នៃសាលក្រុមរបស់តុលាការក្រុងភ្នំពេញចុះថ្ងៃទី១ខែតុលាឆ្នាំ២០១២គឺជារឿងប្រឌិតបទឧក្រិដ្ឋយ៉ាងអយុត្តិធម៌ និងឥតមានលក្ខណៈឡូហ្ស៊ិច(Logic)ត្រង់ណាទាល់តែសោះ ព្រោះថាអ្នកដែលអាចធ្វើអបគមន៍ប្រឆាំងរដ្ឋាភិបាលទៅបាន ទាល់តែលក្ខណៈជាកងកំលាំងប្រដាប់អាវុធដែលមានអង្គការចាត់តាំងត្រឹមត្រូវ បំពាក់ដោយសព្វាវុធទំនើបៗមានរថក្រោះ, យន្តហោះចំបាំង, កាំភ្លើងធំ,កប៉ាល់ចំបាំងនិងគ្រាប់មីស៊ីលគ្រប់គ្រាន់បរិបូណ៌ ទើបអាចធ្វើអបគមន៍ប្រឆាំងនឹងរដ្ឋាភិបាលមួយបាន ចុះចំណែក**លោកប៊ុន-រដ្ឋា** ខ្វះខាតសព្វគ្រប់ សូម្បីតែតំរូវការមូលដ្ឋានសំរាប់ការរស់នៅផ្ទាល់ខ្លួន ក៏គ្មានដែរ តើលោក**ប៊ុន-រដ្ឋា** ទៅធ្វើអបគមន៍យ៉ាងដូចម្តេចកើត? នេះគ្រាន់តែជា«**ល្បិចសំលាប់មួយ គំរាម១000 !**»របស់រដ្ឋាភិបាលហ៊ុនសែនតែប៉ុណ្ណោះ ដើម្បីបំបាក់ស្មារតីអ្នកជាតិនិយមខ្មែរអោយភ័យបាក់ស្បាតរាងចាលលែងហ៊ានធ្វើបដិវត្តរំដោះជាតិខ្មែរតទៅទៀតតែប៉ុណ្ណោះ!។

**UNHCR in Thailand Email** : thaba@unhcr.org

ធ្វើនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៣

ដោយជនរងគ្រោះ **ឡៅ-ណារិទ្ធ**